ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កំណត់ហេតុ

## ប្រជុំផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីសម្រាប់ការស្នើសុំទារកករណីពពោះជំនួសដើម្បីយកទៅចិញ្ចឹមនៅក្រៅប្រទេស

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែកក្កដា ថ្ងៃទីម្ភៃប្រាំ វេលាម៉ោងដប់បួន និងសាមសិបនាទីរសៀល នៅទីស្តីការក្រសួងមហាផ្ទៃ មានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីសម្រាប់ការស្នើសុំទារកករណីពពោះជំនួសដើម្បីយកទៅចិញ្ចឹមនៅក្រៅប្រទេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអញ្ជើញចូលរួមពីតំណាងស្ថានទូតមួយចំនួនប្រចាំព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីការអញ្ជើញមកដល់សាលប្រជុំ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានមានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងតំណាងស្ថានទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសហការី ដែលមានវត្តមាននៅក្នុងអង្គប្រជុំនាពេលនេះ។ សម្តេច មានប្រសាសន៍លើកឡើងអំពីបញ្ហាពពោះជំនួសដែលកំពុងកើតមាននៅប្រទេសកម្ពុជា ក៏ដូចជានៅក្នុងប្រទេសមួយចំនួនទៀតផងដែរ ដែលជាបញ្ហាមួយត្រូវធ្វើការសហការដោះស្រាយព្រោះវាក៏ជាប្រភេទ នៃអំពើជួញដូរមនុស្ស។ ដូច្នេះថ្ងៃនេះយើងជួបជុំគ្នាទាំងមន្ត្រីជំនាញក្នុងរាជរដ្ឋាភិបាលកម្ពុជា ទាំងមិត្តភក្តិបរទេសតំណាងស្ថានទូតមួយចំនួនផងដែរ។ ជាកិច្ចចាប់ផ្តើម សម្តេចក្រឡាហោម បានអនុញ្ញាតឲ្យ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ធ្វើសេចក្តីរាយការណ៍ និងអានសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ២៥៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ ស្តីពី គោលការណ៍ដោះស្រាយករណីទារកដែលកើតដោយការជួលស្ត្រីខ្មែរឲ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស ជូនអង្គប្រជុំ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអានសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ២៥៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ ស្តីពី គោលការណ៍ដោះស្រាយករណីទារកដែលកើតដោយការជួលស្ត្រីខ្មែរឲ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស ជូនអង្គប្រជុំដូចខាងក្រោម៖ រាជរដ្ឋាភិបាលបានសម្រេចក្នុងពេលរង់ចាំការរៀបចំ និងអនុម័តច្បាប់

ស្តីពីការពពោះការដោះស្រាយបញ្ហាចំពោះមុខត្រូវផ្អែកលើគោលការណ៍ចម្បងពីរៈ

ទី១.ធានានូវការអនុវត្តតួនាទីរបស់អាជ្ញាធររដ្ឋក្នុងការការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូរបស់ពលរដ្ឋខ្លួន ជាពិសេសលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដើម្បីកុំឲ្យកម្ពុជាក្លាយជាគោលដៅ នៃការធ្វើអាជីវកម្មពពោះជំនួស។

ទី២.ធានាផលប្រយោជន៍របស់ទារកចេញដោយកកំណើត ឬដែលបានកើតមកហើយ។ ផ្អែកលើគោលការណ៍នេះ ដំណោះស្រាយចំពោះបញ្ហាខាងលើក្នុងពេលចំពោះមុខ ត្រូវអនុវត្តទៅតាមត្រឹមកម្រិតច្បាប់ដែលយើងមានបច្ចុប្បន្ន និងដាក់ចេញវិធានការណ៍រឹតបន្តឹងមួយចំនួនតទៅៈ

វិធានការទី១.ការនាំយកទារកចេញទៅប្រទេសក្រៅអាចអនុញ្ញាតដើម្បីជាផលប្រយោជន៍សម្រាប់ទារក ប៉ុន្តែការនាំយកចេញនេះត្រូវអនុវត្តដោយអនុលោមតាមច្បាប់រដ្ឋប្បវេណីរបស់កម្ពុជាគឺៈ

-ក្នុងករណីស្ត្រីពពោះមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ កូនដែលកើតមកត្រូវសន្មតថាជាកូនរបស់ប្តីនៃស្ត្រីពពោះ។ ឪពុកដែលជាម្ចាស់មេជីវិតចាំបាច់ត្រូវប្តឹងទៅតុលាការដើម្បីទាមទារបិតុភាព(ភាពជាឪពុក) លើទារកនោះតាមផ្លូវច្បាប់ដោយបង្ហាញភស្តុតាងកោសល្យវិច្ច័យលើ DNA ។

-ក្នុងករណីស្ត្រីពពោះនៅលីវ ឬពុំមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ឪពុកដែលជាម្ចាស់មេជីវិតត្រូវប្តឹងទៅតុលាការសុំសិទ្ធគ្រប់គ្រងកូន ដើម្បីអាចនាំកូននោះទៅក្រៅប្រទេសកម្ពុជាបាន។ ការសម្រេចអនុញ្ញាតនឹងអាចធ្វើបានដោយតុលាការ ប្រសិនបើស្ត្រីពពោះព្រមព្រៀងប្រគល់កូននោះឲ្យទៅឪពុកជាម្ចាស់មេជីវិតគ្រប់គ្រង។ កិច្ចសន្យាពពោះមិនអាចយកមកធ្វើជាមូលដ្ឋានកំណត់ការព្រមព្រៀងនេះបានទេ ព្រោះជាកិច្ចសន្យាខុសច្បាប់។

-ដោយឡែកចំពោះវិធានការព្រហ្មទណ្ឌ គឺនៅតែបន្តអនុវត្តចំពោះករណីជនល្មើសដែលជាអន្តរការី នៃការពពោះជំនួសស្របតាមមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ។

វិធានការទី២.ដើម្បីទប់ស្កាត់ការកើតឡើងនូវករណីថ្មី និងការពារមិនឲ្យកម្ពុជាក្លាយជាគោលដៅ នៃអាជីវកម្មជួញដូរទារក ដំណោះស្រាយនេះនឹងត្រូវបានកំណត់តែចំពោះទារក ដែលមានកំណើតក្នុងផ្ទៃរួចហើយ គិតចាប់ពីថ្ងៃចេញផ្សាយគោលការណ៍នេះតទៅរហូតដល់រយៈពេល ៩ខែ១០ក្រោយ ដើម្បីទុកឱកាសឲ្យទារកដែលមានកំណើតរួចហើយទទួលបានការការពារ ហើយទន្ទឹមនឹងនេះការចេញប្រកាសហាមឃាត់ការពពោះជំនួស គឺជាការចាំបាច់អមដោយការរឹតបន្តឹងវិធានការរដ្ឋបាល ពិសេសការត្រួតពិនិត្យតាមគ្លីនិកមួយចំនួន ដែលមានបច្ចេកវិទ្យាពាក់ព័ន្ធនឹងការពពោះ។ បន្ទាប់មកលោកជំទាវ បានបញ្ជាក់បន្ថែមអំពីគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីសម្រាប់ការស្នើសុំទារកករណី នៃការពពោះជំនួសដើម្បីយកទៅចិញ្ចឹមនៅក្រៅប្រទេស សម្រាប់អ្នកស្នើសុំកូនជាជនបរទេសដែលអះអាងថាជាឪពុក ត្រូវដាក់សំណុំលិខិតស្នើសុំតាមរយៈស្ថានទូត ឬស្ថានតំណាងរបស់ខ្លួនប្រចាំនៅកម្ពុជា ដែលឯកសារនីមួយៗ ត្រូវតែមានសុពលភាពយ៉ាងយូរ០៦ខែ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។ ឯកសារទាំងនេះត្រូវមានការបញ្ជាក់ពីភាពត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច ឬស្ថានទូត នៃប្រទេសសាមីរបស់អ្នកស្នើសុំ។

**សម្តេចក្រឡាហោម ស ខេង** មានប្រសាសន៍បន្ថែមទៀតថា នេះជាគោលការណ៍ចំពោះមុខរបស់រាជរដ្ឋាភិបាលកម្ពុជា សម្តេចក៏បានលើកឡើងថា ខ្ញុំបានទទួលព័ត៌មានតែក៏មិនច្បាស់អំដែរ មានប្រទេសមួយចំនួនបាន

ហាមឃាត់ ប្រទេសមួយចំនួនទៀតមិនបានហាមឃាត់ទេ ហើយក៏មានប្រទេសមួយចំនួនកើតមានរួចហើយទើបមានការហាមឃាត់តាមក្រោយ តែឥឡូវនេះវាបានមកកើតឡើងនៅក្នុងប្រទេសកម្ពុជា ដូច្នេះយើងត្រូវរកដំណោះស្រាយរួមគ្នាលើបញ្ហាជួញដូរមនុស្សព្រោះទារកក៏ជាមនុស្សដែរ។ សម្តេចបានស្នើដល់ ១.ថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីគ្រប់ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ ត្រូវខិតខំរកដំណោះស្រាយ និងអនុវត្តបង្ការទប់ស្កាត់លើករណីនេះឲ្យបានល្អទាន់ពេល។ ២.សូមឲ្យមានការចូលរួមសហការពីបណ្តាមិត្តភក្តិបរទេសព្រោះបញ្ហាជួញដូរមនុស្ស ក៏ដូចជាបញ្ហាពពោះជំនួសនៅក្នុងប្រទេសកម្ពុជា ដើម្បីជានាភាពស្របច្បាប់ទាំងអស់គ្នាទាំងអ្នកស្នើសុំ និងអ្នកពពោះត្រូវឆ្លងកាត់តុលាការ។ នេះជាការចាំបាច់ព្រោះយើងមិនដឹងថាគេយកទារកនោះទៅណាទេ មានស្ថានភាពបែបណា បើមានបញ្ហាតើយើងទៅរកឯណា? បើគេយកទារកនោះទៅលក់ដូរ គេនឹងចោទថាកម្ពុជាក៏បានចូលរួមដែរ។ សម្តេចបានបន្ថែមទៀតថា ឥឡូវមានការលក់ដូរមេជីវិត យកមេជីវិតនោះទៅជួលឲ្យស្ត្រីពពោះ ពេលទារកកើតមកអ្នកស្នើសុំទារកនោះមិនសូវយកចិត្តទុកដាក់ ស្រលាញ់ថ្នាក់ថ្នមដូចកូនបង្កើតរបស់ខ្លួននោះទេ។ សព្វថ្ងៃយើងកំពុងតែដោះស្រាយបញ្ហាដែលមានស្រាប់ពាក់ព័ន្ធករណីពពោះជំនួសនេះ តែមានមួយចំនួនបានចេញរួចទៅហើយប្រហែល០៧ករណីយើងបាន និងកំពុងធ្វើការហាមឃាត់ដើម្បីដោះស្រាយ សម្របសម្រួលដល់បណ្តាប្រទេសមិត្តបរទេសមួយចំនួនដែលជាអ្នកស្នើសុំ។ ឥឡូវយើងកំពុងរៀបចំច្បាប់នេះ ដោយទុកឲ្យក្រសួងកិច្ចការនារីជាអ្នកដឹកនាំសរសេរចេងក្រង ជាមួយនឹងក្រសួងយុត្តិធម៌ជាអ្នកសម្របសម្រួល និងអនុវត្ត។

**តំណាងស្ថានទូត អូស្ត្រាលី** បានលើកឡើងចោទជាសំនួរចំនួន០៣ ពាក់ព័ន្ធការស្នើសុំទារកនេះ

១.តើអ្នកស្នើសុំកូនត្រូវមានឯកសារពាក់ព័ន្ធអ្វីខ្លះក្នុងដំណើរការនេះ(សុំកូន)?

២.តើស្ថានទូតសាមី នៃអ្នកស្នើសុំ ត្រូវមានតួនាទីអ្វីខ្លះក្នុងការបំពេញបែបបទសម្រាប់អ្នកស្នើសុំទារក?

៣.តើឪពុកម្តាយទារកនោះអាចកើតមានបញ្ហាប្រឈមដែរទេ ក្នុងការផ្តល់ភាពស្របច្បាប់ ឬពាក់ព័ន្ធនឹងច្បាប់របស់តុលាការ?

**លោកជំទាវ ជូ ប៊ុនអេង** បានធ្វើការឆ្លើយតបនឹងសំនួររបស់តំណាងស្ថានទូតអូស្ត្រាលីដូចខាងក្រោមះ

១.អ្នកស្នើសុំទារកត្រូវមានលិខិតបញ្ជាក់ទីលំនៅអចិន្ត្រៃយ៍ច្បាស់លាស់ ពាក្យស្នើសុំត្រូវមានបិទរូបថតអ្នកស្នើសុំ លិខិតបញ្ជាក់ពីស្ថានភាពគ្រួសារ លិខិតថ្កោលទោស ជាពិសេសអ្នកស្នើសុំត្រូវធ្វើការផ្តល់ព័ត៌មានស្តីពីការវិវត្តន៍លូតលាស់កាយសម្បទា ប្រាជ្ញាស្មារតី របស់ទារកហូតដល់អាយុ១៨ឆ្នាំ តាមរយៈស្ថានទូតកម្ពុជាប្រចាំនៅប្រទេសសាមី...។ល។

២.ស្ថានទូត នៃប្រទេសសាមីត្រូវធ្វើលិខិតបញ្ជូនសំណុំឯកសារទាំងអស់នេះទៅរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីត្រួតពិនិត្យ និងបញ្ជូនទៅក្រសួងមហាផ្ទៃ។

៣.ចំពោះបញ្ហាប្រឈមរបស់ឪពុកម្តាយពាក់ព័ន្ធនឹងច្បាប់របស់តុលាការ ខ្ញុំមិនអាចឆ្លើយបានថាមានបញ្ហាប្រឈម ឬមិនមាននោះទេ វាស្ថិតនៅលើតុលាការជាអ្នកសម្រេច និងសម្របសម្រួលថាតើការពិនិត្យ DNA ពិតឬមិនពិត។ លោកជំទាវបានបន្ថែមថា មានទារកមួយចំនួនបានចាកចេញរួចហើយ ដូច្នេះយើងខ្ញុំចង់បានកិច្ចសហការគ្នា

ជាមួយមិត្តភក្តិបរទេសក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងករណីពពោះជំនួស ព្រោះមានករណីស្ត្រីខ្មែរ ដែលកំពុងពពោះធ្វើដំណើរចេញទៅក្រៅប្រទេស រហូតទារកកើតនៅទីនោះរួចហើយ ពេលគាត់ត្រឡប់មកវិញគឺមិនបាននាំយកទារកនោះមកទេ គឺគាត់មកវិញដៃទទេ។

ចុងបញ្ចប់ នៃអង្គប្រជុំ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** មានប្រសាសន៍ជូនពរដល់សមាជិកអង្គប្រជុំទាំងជាតិ និងអន្តរជាតិ ជាតំណាងក្រសួង ស្ថាប័ន តំណាងស្ថានទូតប្រចាំព្រះរាជាណាចក្រកម្ពុជាព្រមទាំងសហការីទាំងអស់ ជួបតែសេចក្តីសុខ និងទទួលបានជ័យជំនះគ្រប់ភារកិច្ច។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ១៥ និង៥៥នាទីរសៀល ថ្ងៃខែឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧

**អ្នកធ្វើកំណត់ហេតុ**

**គោរពជូន**

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧

**ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប**

**ឧត្តមសេនីយ៍ទោ.គង់-ពុទ្ធី**

27/07/17

**ជុំ-ម៉ុនអេង**

## សមាសសភាពអញ្ជើញចូលរួម

## ប្រជុំផ្សព្វផ្សាយ គោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីសម្រាប់ការស្នើសុំទារក ករណីពពោះជំនួសដើម្បីយកទៅចិញ្ចឹមនៅក្រៅប្រទេស

## ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

ថ្ងៃអង្គារ៍ ទី២៥ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង១៤:៣០នាទី រសៀល នៅទីស្តីការក្រសួងមហាផ្ទៃ (អាគារ A)

| | | | |
|---|---|---|---|
| ១.លោកជំទាវ | ជូ | ប៊ុនអេង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| ២.ឯកឧត្តម | ស៊ូ | ភិរិន្ទ | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី |
| ៣.លោកជំទាវ | សាន្ត | អរុណ | រដ្ឋលេខាធិការក្រសួងកិច្ចការនារី |
| ៤.ឯកឧត្តម | អេង | ហួត | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ៥.ឯកឧត្តម | ស៊ា | កុសល | អនុរដ្ឋលេខាធិការក្រសួងការបរទេស |
| ៦.ឯក.ឧ នាយឧត្តមសេនីយ៍ | សុខ | ផល | អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ៧.ឯក.ឧ នាយឧត្តមសេនីយ៍ | ម៉ៅ | ច័ន្ទតារា | អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៨.ឯក.ឧត្តមសេនីយ៍ឯក | ប៉ោ | កក្កិ | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ |
| ០៩.ឯកឧត្តម | ប៉ែន | ពេជ្រសាលី | អគ្គនាយក ក្រសួងយុត្តិធម៌ |
| ១០.ឯក.នាយ.ឧ | គៀត | ច័ន្ទថារិទ្ធ | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ១១.ឯក.ឧត្តមសេនីយ៍ឯក | ខៀវ | ចាន់ព៉ា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១២.លោកជំ.ឧត្តមសេនីយ៍ | ប៊ុណ្ណ | សំខាន់ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១៣.ឯក.ឧត្តមសេនីយ៍ឯក | ស៊ុន | រ៉ូ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១៤.ឯក.ឧត្តមសេនីយ៍ឯក | យ៉ែម | ច័ន្ទណារ៉ុំ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១៥.ឯក.ឧត្តមសេនីយ៍ទោ | អ៊ូ | ម៉ានីព៉ា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១៦.លោកជំទាវ | រ៉ែន | សិរិលក្ខិណា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១៧.លោកឧត្តមសេនីយ៍ទោ | គង់ | ពុទ្ធី | ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប គ.ជ.ប.ជ |
| ១៨.លោកស្រី | ព្រុំ | សុខន | ប្រធាននាយកដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន |
| ១៩.លោកវរសេនីយ៍ឯក | កែវ | សុវណ្ណារ៉ា | ប្រធាននាយកដ្ឋានបង្ការទប់ស្កាត់ គ.ជ.ប.ជ |
| ២០.លោក | អ៊ឹង | វណ្ណថា | ប្រធាននាយកដ្ឋាន ក្រសួងការបរទេស |
| ២១.លោក | RAJIV | KUMAR | EMBASSY OF INDIA |
| ២២.លោក | DANIEL | XIMENES | EMBASSY OF TIMOR-LESTE |
| ២៣.លោក | STUGAWA | TAKAHISA | EMBASSY OF JAPAN |
| ២៤.លោក | RUZAINI | MOHAMAD | EMBASSY OF MALAYSIA |

| | | |
|---|---|---|
| ២៥.លោកស្រី | THIN Pyant Thida Kyan | EMBASSY OF MYANMAR |
| ២៦.លោកស្រី | Lotta Dacobsen | EMBASSY OF SWEDEN |
| ២៧.លោកស្រី | MADE Santi Ratnasari | EMBASSY OF INDONESIA |
| ២៨.លោកស្រី | LAUREN Tuohy | EMBASSY OF AUSTRALIA |
| ២៩.លោកស្រី | Gritlida Sujira | EMBASSY OF ROYAL THAI |
| ៣០.លោកស្រី | Suzianth Abdul Latip | EMBASSY OF BRUNEI |
| ៣១.លោកស្រី | LI YAN | EMBASSY OF CHINA |
| ៣២.លោកស្រី | Angela Harley | U.S EMBASSY |
| ៣៣.លោក | Graemme HarRow | BRITISH OF EMBASSY |
| ៣៤.លោកស្រី | Monika Kamille Limpo | EMBASSY OF PHILIPPINE |
| ៣៥.លោកស្រី | Chow PEI Shang | EMBASSY OF SINGAPORE |
| ៣៦.លោក | Vieng PHATHAY Sisavath | LAO PDR OF EMBASSY |

និងលោក លោកស្រី ដែលជាសហការីមកពីក្រសួង ស្ថាប័ន និងស្ថានទូត មួយចំនួនទៀត
សរុបចំនួន ៦១រូប ស្រី ២២រូប